Looking back & moving forward

*"A society cannot know itself if it does not have an accurate memory of its own history."*

# Stop sulking and move on

Sok-Kheang Ly,

Located in an 18-hectare plot of land covered by numerous species of tree, beds of vegetable garden, and dotted with old and separate buildings, the Royal University of Agriculture hosted approximately 600 students from various backgrounds in a huge and nice conference hall to listen to the deputy of the Documentation Center of Cambodia (DC-Cam) Dara P. Vanthan in the discussion, Q&A forum and an introduction to the website www.cambodiatribunal.org, which is launched to guide the students on how to use the important tools to log in, read and retrieve information about the Khmer Rouge tribunal.

Graduated from Notre Dame Law School in 2005, Mr. Vanthan showed students the information in the website such as blogs, news, multimedia, Extraordinary Chambers in the Court of Cambodia & NGO report, trial proceedings, history, tribunal background, and commentary pages.

During the meeting, students voiced different views and asked several questions about the Khmer Rouge history and tribunal.

One student began by wondering why the Khmer Rouge regime ruled the country and made all Cambodians betray their consciences. Phim Meng Hak, a foundation year student, wanted an explanation as to why the Khmer Rouge needed to keep every record of each prisoner at S-21. Another foundation year student Heng Seng Pheang expressed his curiosity about whether Case 003 would be brought to trial. Mr. Vanthan responded to those questions afterwards.

Also at the conference, two documentary films were screened. One was about S-21 prison shot by the Vietnamese in January 1979 and another was DC-Cam-produced film titled "Behind the Walls of S-21: Oral Histories from Tuol Sleng Prison." The purpose of the films, discussions, and Q&A forums were to raise awareness among university students about the proceeding at the Khmer Rouge tribunal. As more than three decades has passed, it is time that survivors and their children move forwards to more prosperous future by learning from the past and avoid the past atrocities. LIFT

> "It is not time-consuming and I can learn to make use of technology."



Teachers instructing and students learning how to better their learning of Khmer Rouge history. SOCHEAT NHEAN

សាកលវិទ្យាល័យភូមិន្ទកសិកម្មមានទីតាំងនៅលើផ្ទៃដីដែលមានទំហំ ១៨ ហិកតា គ្របដណ្តប់ដោយដើមឈើ សួនបន្លែ និងអគារចាស់ៗនិងអគារថ្មីៗជាច្រើនខ្នង។ នៅទីនោះ បានរៀបចំសិក្ខាសាលាមួយដល់និស្សិតប្រមាណជា៦០០នាក់ ដែលមកពីគ្រប់ជំនាញដើម្បីស្តាប់ការពិភាក្សា កម្មវិធីសំណួរនិងចម្លើយ ព្រមទាំងបទបង្ហាញពីគេហទំព័រឃ្លាំមើលដំណើរការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ដែលសម្របសម្រួលដោយលោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

គោលបំណងសំខាន់របស់សិក្ខាសាលានេះគឺដើម្បីណែនាំដល់និស្សិត អំពីការប្រើប្រាស់គេហទំព័រខាងលើនេះ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានបង្ហាញនិស្សិតទាំងអស់ពីព័ត៌មានដែលមាននៅក្នុងគេហទំព័រនេះ មានដូចជា ប្លុក ព័ត៌មានថ្មីៗ ព័ត៌មានចម្រុះ របាយការណ៍របស់សាលាក្តីខ្មែរក្រហម និងស្ថាប័នក្រៅរដ្ឋាភិបាលផ្សេងៗ ដំណើរការនីតិវិធីរបស់តុលាការ ប្រវត្តិសាស្រ្ត ប្រវត្តិសង្ខេបពីការកកើតឡើងរបស់តុលាការ និងអត្ថបទវិភាគផ្សេងៗទៀត។

នៅក្នុងសិក្ខាសាលានេះ និស្សិតជាច្រើនបានបញ្ចេញមតិយោបល់ខុសៗគ្នា ហើយបានសួរសំណួរជាច្រើនទាក់ទិនទៅនឹងប្រវត្តិកម្ពុជាប្រជាធិបតេយ្យ និងតុលាការខ្មែរក្រហម។

មាននិស្សិតម្នាក់ឆ្ងល់ថា ហេតុអ្វីបានជារបបខ្មែរក្រហមដឹកនាំប្រទេស និងប្រជាជនខ្មែរក្បត់ឧត្តមគតិរបស់ខ្លួនឯងទៅវិញ? ចំណែកឯនិស្សិត ភឹម ម៉េងហាក់ ចង់បានការពន្យល់បកស្រាយ ពីមូលហេតុដែលខ្មែរក្រហមចាំបាច់ត្រូវធ្វើការកត់ត្រាព័ត៌មានរបស់អ្នកទោសនីមួយៗ នៅមន្ទីរស-២១។ ជាមួយគ្នានេះដែរ និស្សិតថ្នាក់មូលដ្ឋាន ហេង សេងភៀង ចង់ដឹងថាតើសំណុំរឿងលេខ០០៣ អាចនឹងត្រូវបាននាំមកជំនុំជម្រះទោសដែរឬទេ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានឆ្លើយតបទៅនឹងសំណួរទាំងនោះយ៉ាងក្បោះក្បាយ។

ជាងនេះទៅទៀត នៅក្នុងសិក្ខាសាលានេះ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចាំងខ្សែភាពយន្តឯកសារចំនួនពីរគឺ ទីមួយនិយាយពីអ្នកទោសមន្ទីរស-២១ដែលត្រូវបានថតដោយកងយោធាវៀតណាមនៅខែមករា ឆ្នាំ១៩៧៩ និងខ្សែភាពយន្តមួយទៀតគឺ មានចំណងជើងថា៖ «ក្រោយជញ្ជាំងមន្ទីរ ស-២១: ប្រវត្តិផ្ទាល់មាត់ពីគុកទួលស្លែង» ដែលត្រូវបានផលិតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ គោលបំណងនៃការបញ្ចាំងខ្សែភាពយន្ត ការពិភាក្សា និងកម្មវិធីសំណួរចម្លើយនេះគឺ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់និស្សិតមហាវិទ្យាល័យពីដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហម។ អស់រយៈពេលសាមសិបឆ្នាំ បានកន្លងផុតទៅ នេះគឺជាពេលដែលអ្នករស់រានមានជីវិត និងកូនចៅជំនាន់ក្រោយដើរឆ្ពោះទៅមុខទៅរកអនាគតរុងរឿងមួយតាមរយៈការរៀនសូត្រពីអតីតកាលរបស់ខ្លួន ដើម្បីចៀសឲ្យផុតនូវអតីតកាលដ៏កាចសាហាវទាំងនោះ៕